**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA

Kingdom of Wonder

feel the warmth

**ក្រសួងទេសចរណ៍**

លេខ ០១០ ទសណន

ថ្ងៃ អង្គារ ៧រោច ខែ ចេត្រ ឆ្នាំ ជូត ទោស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ មេសា ឆ្នាំ២០២០

**សេចក្តីណែនាំ ស្តីពី**

**វិធានការការពារការចម្លងវីរុសកូវីដ១៩** (Covid-19)

**សម្រាប់អាជីវកម្មទីលានវាយកូនគោល** (Golf Course)

ដើម្បីទប់ស្កាត់ការចម្លង **វីរុសកូវីដ១៩** (Covid-19) ឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត និងការចូលរួមការពារការចម្លងវីរុសកូវីដ១៩នៅតាមបណ្តាអាជីវកម្មទីលានវាយកូនគោលទាំងអស់ដែលទទួលបានអាជ្ញាបណ្ណពីក្រសួងទេសចរណ៍ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្រសួងទេសចរណ៍សូមធ្វើការណែនាំចំពោះអ្នកគ្រប់គ្រង បុគ្គលិកបម្រើការ និងកីឡាករ កីឡាការិនីវាយកូនគោល ត្រូវអនុវត្តទៅតាមវិធានការណ៍នានាដែលរាជរដ្ឋាភិបាលកម្ពុជា ក្រសួងសុខាភិបាល និងក្រសួងអប់រំ យុវជន និងកីឡាបានណែនាំ ជាពិសេសត្រូវអនុវត្តតាមគោលការណ៍បន្ថែមមួយចំនួនទៀត ដូចខាងក្រោម៖

- មិនត្រូវរៀបចំឱ្យមានជាព្រឹត្តិការណ៍ ឬការប្រកួតដណ្តើមពានរង្វាន់កីឡាវាយកូនគោលឡើយ
- ត្រូវមានកន្លែងសមរម្យដើម្បីត្រួតពិនិត្យកម្តៅបុគ្គលិកបម្រើការ និងកីឡាករ កីឡាការិនី មុនអនុញ្ញាតឱ្យចូលលេង
- តម្រូវឱ្យឡានកូនគោល (Golf Cart) មួយសម្រាប់ភ្ញៀវលេងម្នាក់ និងបុគ្គលិក (Caddy) ម្នាក់ឈរខាងក្រោយ
- ត្រូវរក្សាគម្លាតចម្ងាយនៅឱ្យឆ្ងាយពីគ្នាស្របតាមគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាល និងធ្វើការសម្អាតសម្ភារៈឧបករណ៍លេងទាំងអស់ជាមួយទឹកអាល់កុលជាប្រចាំ មុនពេល អំឡុងពេល និងក្រោយពេលប្រើប្រាស់ដើម្បីសម្លាប់មេរោគ និងហាមចាប់ដៃស្វាគមន៍ ជំនួសដោយការលើកដៃសំពះគ្នាទៅវិញទៅមក
- ត្រូវពាក់ម៉ាស់ឱ្យបានត្រឹមត្រូវ គ្រប់ពេលវេលា និងធ្វើការត្រួតពិនិត្យ លាងសម្អាតដោយទឹកអាល់កុលលើសម្ភារៈទាំងអស់របស់ខ្លួន មុនពេលដាក់ចូលទៅក្នុងឡានវាយកូនគោល (Golf Cart)
- មិនអនុញ្ញាតឱ្យលេងលើសពី ៤នាក់ ក្នុង១ក្រុម និងអាចយកបុគ្គលិក (Caddy) តែម្នាក់ប៉ុណ្ណោះសម្រាប់កីឡាករ កីឡាការិនីម្នាក់ៗ និងមិនអាចប្រើប្រាស់ ឬប៉ះពាល់ឧបករណ៍សម្ភារៈក្រៅពីរបស់ផ្ទាល់ខ្លួន។

សេចក្តីណែនាំនេះត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពរហូតដល់មានការជូនដំណឹងជាថ្មីអំពីស្ថានភាពការឆ្លងវីរុសកូវីដ១៩ (Covid-19)។

សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័ររបស់នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង នៃក្រសួងសុខាភិបាល www.cdcmoh.gov.kh ឬតាមរយៈលេខទូរស័ព្ទទាន់ហេតុការណ៍ Hotline ១១៥ ដោយឥតគិតថ្លៃ និងនាយកដ្ឋានគ្រប់គ្រងសេវាកម្សាន្ត និងកីឡាទេសចរណ៍នៃក្រសួងទេសចរណ៍ ( ០១១ ៨៣ ៣៣ ១៨)។

**ក្រសួងទេសចរណ៍**